# អនុសញ្ញាស្តីពីសិទ្ធិកុមារ

# *The Convention on the Rights of the Child*



# តើអ្នកណាជាកុមារ?

## ១-   និយមន័យ "កុមារ"

យោងតាមមាត្រា១នៃអនុសញ្ញាអ.ស.ប.ស្តីពីសិទ្ធិកុមារ ចែងថា""កុមារ" គឺជាមនុស្សគ្រប់រូបដែលមានអាយុតិចជាង១៨ឆ្នាំ លើកលែងតែអាយុពេញវ័យត្រូវបានកំណត់រហ័សជាង នេះនៅក្នុងច្បាប់នៃប្រទេសនីមួយៗ។ មាត្រានេះជាមាត្រាលើកលែងមួយ ព្រោះវាមានការលំបាកក្នុងការកំណត់ឱ្យបានឯកភាពគ្នាអំពីពេលចាប់ផ្តើម និងពេលបញ្ចប់នៃកុមារភាព ដោយសារប្រទេសនៅលើពិភពលោកមានជំនឿ សាសនា វប្បធម៌ និងទំនៀមទំលាប់ ប្រពៃណីខុសៗគ្នា។

# សំណួរពិភាក្សា

## រយៈពេល១៥នាទី

- តើកុមារ និងមនុស្សចាស់ខុសគ្នាយ៉ាងដូចម្ដេចខ្លះ?

# ២ -ហេតុអ្វីបានជាយើងត្រូវរៀន និងយល់ដឹងពីសិទ្ធិកុមារ?

## តើកុមារ និងមនុស្សចាស់ខុសគ្នាយ៉ាងដូចម្តេចខ្លះ?

| កុមារ | | មនុស្សចាស់ |
|---|---|---|
| តូច | → | ធំ |
| អាចងាយរងគ្រោះជាង | | មិនសូវងាយរងគ្រោះជាង |
| ប្រាជ្ញាស្មារតីអន់ជាង | | ប្រាជ្ញាស្មារតីប្រសើរជាង |
| ងាយគេអូសទាញ | | មិនងាយគេអូសទាញបាន |
| លេងសើចច្រើន | | មិនសូវលេងសើចច្រើន |
| ត្រូវការការថែទាំ ដើម្បីលូតលាស់ | | មិនត្រូវការការថែទាំ ដើម្បីលូតលាស់ |

# ការអភិវឌ្ឍន៍កុមារ



រូបរាងកាយ
Physical

អារម្មណ៍
Emotion

សីលធម៌
Moral

បញ្ញាស្មារតី
Intellectual

សង្គម
Social

# ៣- ការអភិវឌ្ឍន៍របស់កុមារ

- **ផ្នែករាងកាយៈ** កុមារចាំបាច់ត្រូវការចំណីអាហារដែលមានជីវជាតិគ្រប់គ្រាន់ ការថែទាំសុខភាព ពេលវេលាសម្រាប់លេង និងហាត់ប្រាណ ត្រូវការជម្រក និងសំលៀកបំពាក់ជាដើម។ល។
- **ផ្នែកអារម្មណ៍ៈ** កុមារចាំបាច់ត្រូវការបរិយាកាសល្អ និងរីករាយ សេចក្តីស្រឡាញ់ ការយកចិត្តទុកដាក់ថែទាំពីក្រុមគ្រួសារ ការលើកទឹកចិត្ត និងមិនត្រូវឱ្យមានការរំលោភបំពាន គំរាមកំហែងឡើយ។

- **ផ្នែកបញ្ញាស្មារតី៖** កុមារត្រូវការបរិយាកាសរៀនសូត្រល្អ ការក្រើនរំលឹកស្មារតី ជាពិសេសពេលវ័យនៅក្មេងត្រូវការការលើកទឹកចិត្ត ចំណីអាហារដែលមានជីវជាតិ ឱកាសសិក្សារៀនសូត្រ លេងកម្សាន្តសប្បាយ និងពេលវេលាលំហែ។ល។
- **ផ្នែកសីលធម៌៖** កុមារចាំបាច់ត្រូវការបរិយាកាសល្អ គំរូល្អពីឪពុកម្តាយ និងក្រុមគ្រួសារ យល់ដឹងអំពីការខុស និងត្រូវ។ល។
- **ផ្នែកសង្គម៖** កុមារចាំបាច់ត្រូវការគំរូល្អពីអ្នករស់នៅជុំវិញខ្លួន ការប្រាស្រ័យទាក់ទងល្អជាមួយក្រុមគ្រួសារ មានឱកាសជួបជុំ និងមានទំនាក់ទំនងល្អជាមួយអ្នកដទៃ ត្រូវការការចូលរួមផ្តល់យោបល់ និងចូលរួមធ្វើសកម្មភាពសមស្របនានានៅក្នុងសង្គម។

# ទន្និមនឹងនេះកុមារតំរូវការ:

- **គ្រួសារ**
  - បរិយាកាសគ្រួសារល្អ　　- ការថ្នាក់ថ្នម
  - ភាពជិតស្និទ្ធ កក់ក្ដៅ　　- ការអប់រំផ្សេងៗ
- **បទពិសោធថ្មីៗ**
  - ការផ្ទេរចំណេះដឹងពីមនុស្សចាស់
  - ការលេងល្បែងកំសាន្ត
  - ផ្ដល់ឱកាសឱ្យគេបញ្ចេញយោបល់
- **ការទទួលខុសត្រូវ**
  - ផ្ដល់ការងារតូចៗទាំងនៅក្នុងផ្ទះសាលារៀន និងសហគមន៍របស់ពួកគេ
- **ការសរសើរ　និងការទទួលស្គាល់**
  - ស្នាដៃ　　- ផ្ដល់តម្លៃដល់កុមារគ្រប់រូប

# ផលប្រយោជន៍ឧត្តុង្គឧត្តមរបស់កុមារ




អ្នកធ្វើការងារដើម្បីលើកស្ទួយការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារត្រូវយកគោលការណ៍ទាំងនេះមកប្រើប្រាស់ជាមូលដ្ឋានក្នុងការសម្រេចចិត្ត ឬរៀបចំផែនការសកម្មភាពនានាក៏ដូចជាក្នុងពេលអនុវត្តគ្រប់មាត្រាទាំងអស់ដែលមានចែងនៅក្នុងអនុសញ្ញានេះ ។

# ក្រុមសិទ្ធិទាំង៤នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ

១- សិទ្ធិរស់រានមានជីវិត

- ការថែទាំសុខភាព
- ការបំប៉នចំណីអាហារ
- ជម្រក
- សន្តិសុខសង្គម

២- សិទ្ធិក្នុងការអភិវឌ្ឍ

- ការអប់រំ
- ការលេងកំសាន្ត និងលំហែ
- ការទទួលព័ត៌មានសមស្របផ្សេងៗ
- ការស្រឡាញ់ថ្នាក់ថ្នម

## ៣- សិទ្ធិទទួលការការពារ

- ការការពារពីការកេងប្រវ័ញ្ចលើផ្លូវភេទ
- ការការពារពីការប្រើប្រាស់គ្រឿងញៀន
- ការការពារពីការធ្វើពលកម្មធ្ងន់ធ្ងរ
- ការការពារពីអំពើហិង្សាគ្រប់រូបភាព
- ការការពារពីការរើសអើង

## ៤- សិទ្ធិក្នុងការចូលរួម

- ការបញ្ចេញមតិយោបល់
- ការចូលរួមបង្កើតក្រុម ឬសមាគម
- ការចូលរួមផ្សព្វផ្សាយពត៌មាន
- ការចូលរួមក្នុងសកម្មភាពសង្គម

# ការទទួលខុសត្រូវលើកុមារ

- ឪពុកម្ដាយ
- គ្រួសារ
- សហគមន៍មូលដ្ឋាន
- អាជ្ញាធរមូលដ្ឋាន
- អាជ្ញាធរជាតិ
- អង្គការក្រៅរដ្ឋាភិបាល
- សហគមន៍អន្តរជាតិ



- ការទទួលខុសត្រូវរបស់កុមារ
  - ក្នុងគ្រួសារ
  - ក្នុងសាលារៀន
  - ក្នុងសង្គម
- ការទទួលខុសត្រូវរបស់ឪពុកម្ដាយ ឬគ្រួសារ
- ការទទួលខុសត្រូវរបស់សាលារៀន
- ការទទួលខុសត្រូវរបស់ស្ថាប័នជំនៃ
- ការទទួលខុសត្រូវរបស់សហគមន៍

# សូមអរគុណ!